# កំណត់សំគាល់ ផ្នែកច្បាប់
# ស្ដីពី
# បញ្ជី ភាតព្វកិច្ចផ្នែកច្បាប់
# សម្រាប់ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល( NGOs )

## ប្រវត្តិ

ព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ២០១៥ ប្រកាសឲ្យប្រើច្បាប់ស្ដីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ។

ព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ១៩៩៧ ប្រកាសឲ្យប្រើច្បាប់ស្ដីពី សារពើរពន្ធ ។

ព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ១៩៩៧ ប្រកាសឲ្យប្រើច្បាប់ស្ដីពី ការងារ ។

ព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១៦ ប្រកាសឲ្យប្រើច្បាប់ស្ដីពី គណនេយ្យ និងសវនកម្ម ។

ព្រះរាជក្រមលេខ នស/រកម ០១២១/០០៣ ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០២១ ប្រកាសឲ្យប្រើច្បាប់ស្ដីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគា (អសហ)។

ព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ ២០១៩ ប្រកាសឲ្យប្រើច្បាប់ស្ដីពីរបបសន្តិសុខសង្គម ។

មានច្បាប់និងលិខិតបទដ្ឋានគតិយុត្ត មួយចំនួនទៀតដែលបានបង្កើតឡើង និងបានធ្វើវិសោធនកម្ម ដើម្បីអោយស្រម និងសភាពការជាក់ស្តែង ។

# បញ្ជីភាតព្វកិច្ចផ្នែកច្បាប់ ដែល( NGOs )ត្រូវអនុវត្ត

| **ភាតព្វកិច្ច សមាគម និងអង្គការមិនមែនរដ្ឋាភិបាល (NGOs)** | | **មាត្រា** | **កំណត់សំគាល់ ( ពាក្យគន្លឹះ, ការពន្យល់ )** |
|---|---|---|---|
| **ច្បាប់ស្តីពី សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល( ឆ្នាំ ២០១៥ )** | | | |
| ១ | LNGOs ត្រូវជូនដំណឹងជាលាយលក្ខអក្សរទៅ MOI និង MOEF ពីគណនីធនាគារ (៣០ថ្ងៃ) ក្រោយពីចុះបញ្ជី ។<br>វិសោធនកម្មលក្ខន្តិកៈ ដូរស្នាក់ការ ដូរប្រធាន ប្រែប្រួលគណនីធនាគារ (១៥ថ្ងៃ)ពីដូរ។ | មាត្រា ១០ | LNGOs= សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។<br>MOI= ក្រសួងមហាផ្ទៃ ។<br>MOEF= ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ |
| ២ | NGOs ស្ថិតនៅក្រោមនីតិវិធីនៃ របបសារពើពន្ធ និងទទួលបានការអនុគ្រោះនានា ស្របតាមច្បាប់ ជាធរមាន។ | មាត្រា ២០ | LNGOs= សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវអនុវត្តតាមច្បាប់ស្តីពីសារពើពន្ធ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ។ |
| ៣ | NGOs មានសិទ្ធិចុះកិច្ចសន្យាសហប្រតិបត្តិ ការជាមួយដៃគូរ ក្នុងការអនុវត្តគម្រោងសកម្មភាព។ | មាត្រា ២១ | FNGOs = សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស។<br>MoFA/IC= ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។<br>MOEF= ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ |
| ៤ | NGOs មានសិទ្ធិជ្រើសរើសបុគ្គលិក ឬកម្មករ ស្របតាម ច្បាប់ ស្តីពីអន្តោប្រវេសន៍ ច្បាប់ស្តីពីការងារ និងលិខិតបទដ្ឋានគតិយុត្តនានា ជាធរមាន។ | មាត្រា ២២ | LNGOs= សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវធ្វើសកម្មភាព ស្របតាមច្បាប់ស្តីពីអន្តោប្រវេសន៍ ច្បាប់ស្តីពី |

| | | | |
|---|---|---|---|
| | | | ការងារ និងលិខិតបទដ្ឋានគតិយុត្តនានា ជាធរមាន ។ |
| ៥ | អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និង FNGOs ត្រូវប្រកាន់ជំហរអព្យាក្រិតចំពោះគ្រប់ គណបក្សនយោបាយនៅកម្ពុជា។ | មាត្រា ២៤ | អង្គការមិនមែនរដ្ឋាភិបាល ក្នុងស្រុក (មិនរាប់បញ្ចូលសមាគមក្នុងស្រុក)និង FNGOs ត្រូវប្រកាន់ជំហរអព្យាក្រិតចំពោះគ្រប់ គណបក្សនយោបាយនៅកម្ពុជា។ |
| ៦ | អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវផ្ញើរទៅ MOI និងMOEF នូវរបាយការណ៍ស្តីពីសកម្មភាពនិងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ខ្លួន ឱ្យបានត្រឹមដំណាច់ខែកុម្ភៈ នៃឆ្នាំបន្ទាប់។ | (មាត្រា ២៥ ) | អង្គការមិនមែនរដ្ឋាភិបាល ក្នុងស្រុក (មិនរាប់បញ្ចូលសមាគមក្នុងស្រុក) MOI= ក្រសួងមហាផ្ទៃ ។ MOEF= ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ |
| ៧ | NGOs ឬ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល មិនត្រូវធ្វើសកម្មភាព ដែលនាំអោយប៉ះពាល់ដល់សន្តិសុខជាតិ ឬពាក់ព័ន្ធនិងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវះកម្ម ឬបទល្មើសភេរវកម្ម ឬបទល្មើសព្រហ្ម ទណ្ឌផ្សេងៗទៀត ។ | មាត្រា ៣៦ | NGOs ឬ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល សំដៅដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក (LNGOs) និងសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស (FNGOs) |
| **ច្បាប់ស្តីពីសារពើពន្ធ ( ឆ្នាំ ១៩៩៧)** | | | |
| ១ | NGOs ត្រូវទៅចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ក្នុងរយៈពេល ១៥ ថ្ងៃនៃថ្ងៃធ្វើការ ក្រោយពេលទទួលបានលិខិតបញ្ជាក់ការចុះបញ្ជី ឬលិខិតអនុញ្ញាត្ត ចេញដោយក្រសួងឬ ស្ថាប័នពាក់ព័ន្ធ ។ | មាត្រា ១០១ | មាត្រា ១០១ នៃច្បាប់ស្តីពីសារពើពន្ធ ប្រកាសលេខ ៧០១ សហវ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០២០ ស្តីពីការចុះបញ្ជីពន្ធដា និងការធ្វើបច្ចុប្បន្នភាពពត៌មានអ្នកជាប់ពន្ធ និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងៗ ។ |

| | | | |
|---|---|---|---|
| ២ | NGOs ឬ អ្នកជាប់ពន្ធត្រូវកាន់កាប់ កត់ត្រា និង រក្សាទុកបញ្ជី លិខិតយុត្តិការ និង ឯកសារហិរញ្ញវត្ថុផ្សេងៗ (១០ ឆ្នាំ) និងត្រូវដាក់បញ្ជី និង ឯកសារទាំងនោះតាមការតម្រូវ ជូនរដ្ឋបាល សារពើពន្ធដើម្បីពិនិត្យ ។ | មាត្រា ៩៨ | NGOs = សមាគម និងអង្គការមិនមែនរដ្ឋាភិបាល សំដៅដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក (LNGOs) និងសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស (FNGOs)។ |
| ៣ | NGOs អ្នកជាប់ពន្ធ ជាភ្នាក់ងារកាត់ទុក ត្រូវដាក់លិខិតប្រកាសសារពើពន្ធ ជូនរដ្ឋបាលសារពើពន្ធទៅតាមទម្រង់ ពេលវេលា និងទីកន្លែង ដែលរដ្ឋបាលសារពើពន្ធបានកំណត់ ។<br>លិខិតប្រកាសពន្ធត្រូវចុះហត្ថលេខាដោយអ្នកជាប់ពន្ធឬតំណាងស្របច្បាប់របស់អ្នកជាប់ពន្ធ។ | មាត្រា ១០៤ | ប្រធាន សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ជាភ្នាក់ងារកាត់ទុកដែល ច្បាប់បានកំណត់ និងមានកាតព្វកិច្ចអនុវត្តកាតព្វកិច្ចបង់ពន្ធតាម ច្បាប់ជាធរមាន ។ |
| ៤ | ពន្ធកាត់ទុកលើការជួល៖ NGOs ឬអ្នកជាប់ពន្ធមានកាតព្វកិច្ចជាភ្នាក់ងារកាត់ទុកដោយត្រូវកាត់ទុកតាមអត្រាដូចមានចែងក្នុងមាត្រា២៥ និងមាត្រា២៦ នៃច្បាប់សារពើពន្ធ។ អត្រាពន្ធកាត់ទុកមួយចំនួន ៖<br>អត្រា ១៥ ភាគរយចំពោះ<br>-ប្រាក់ចំណូលដែលរូបវន្តបុគ្គលបានទទួលពីការបំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោ បល់ ឬសេវាប្រហាក់ប្រហែល ។<br>-សួយសារចំពោះទ្រព្យអរូបីនិងភាគកម្មក្នុងធនធានរ៉ែ ហើយនិងការប្រាក់ដែលអ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ដែលមិនមែនជាធនាគារ ឬស្ថាប័នសញ្ច័យធនក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជន<br>អត្រា ១០ ភាគរយ ចំពោះ<br>ប្រាក់ចំណូលពីការឱ្យជួលចលន ឬអចលនទ្រព្យ ។<br>អត្រា ៦ ភាគរយ ចំពោះ | មាត្រា ២៥ និង មាត្រា ២៦ | ពន្ធកាត់ទុកកាតព្វកិច្ចរបស់ភ្នាក់ងារកាត់ទុកដោយត្រូវកាត់ទុក តាម អត្រាដូចមានចែងក្នុងច្បាប់ រួចយកទៅបង់ជូន រដ្ឋបាលសារពើពន្ធ តាមទីកន្លែង និងពេលកំណត់ ។ |

| | | | |
|---|---|---|---|
| | ការប្រាក់ដែលធនាគារ ឬស្ថាប័នសញ្ញ័យក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជនដែល មានគណនីបញ្ញើមានការកំណត់ ។<br>អត្រា ៤ ភាគរយ ចំពោះ<br>ការប្រាក់ដែលធនាគារ ឬស្ថាប័នសញ្ញ័យក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជនដែល មានគណនីសន្សំគ្មានការកំណត់។ | | |
| ៥ | ពន្ធលើប្រាក់បៀវត្ស ៖ សម្រាប់ NGOs ដែលមានបុគ្គលិកត្រូវជាប់ពន្ធ។ | | អនុវត្តទៅតាមសេចក្តីណែនាំលេខ ០១៧ សហវ ចុះថ្ងៃទី ២៧ ធ្នូ ២០២២ ។<br>(សេចក្តីណែនាំនេះ អាចនិងប្រែប្រួលទៅតាមស្ថានភាព សេដ្ឋកិច្ច សង្គមដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច) ។ |
| ៦ | NGOsឬសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ដែលប្រកបអាជីវកម្មដោយឡែកត្រូវ ចុះបញ្ជីតាមសេចក្តីណែនាំលេខ ៣០៣៣ អពដ ចុះថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ ២០២០ ចេញដោយអគ្គនាយកដ្ឋានពន្ធដារ។ | | សេចក្តីណែនាំលេខ ៣០៣៣ អពដ ចុះថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ ២០២០ ចេញដោយអគ្គនាយកដ្ឋានពន្ធដារ។ |
| ៧ | ប្រាក់ចំណូលលើកលែងពន្ធត្រូវបានកំណត់ ក្នុង មាត្រា ៩ ចំនុចទី១ (ខ) នៃច្បាប់ស្តីពីសារពើពន្ធ ឆ្នាំ ១៩៩៧ ចំពោះ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលត្រូវបានរៀបចំឡើងនិងដំណើរការសម្រាប់ គោលដៅ សុទ្ធសាធខាង សាសនា សប្បុរសធម៍ វិទ្យាសាស្រ្ត អក្សរសាស្រ្ត ឬអប់រំ ហើយគ្មាន ចម្មែកណាមួយនៃទ្រព្យ ឬប្រាក់ចំណូលប្រើប្រាស់ជាឯកជន ដែលមានចែងក្នុងលក្ខន្តិក:របស់ខ្លួន ។ | មាត្រា ៩ | គ្រប់ការលើកលែងនិងអនុគ្រោះផ្នែកពន្ធដារទាំងអស់ត្រូវតែមានការស្នើសុំ ទៅរដ្ឋបាលសារពើពន្ធ។ |

| ច្បាប់ស្តីពី ការងារ ( ឆ្នាំ ១៩៩៧) | | | |
|---|---|---|---|
| ១ | NGOs ត្រូវធ្វើសេចក្តីប្រកាសជូនដំណឹង បើក ឬបិទសហគ្រាសឬអង្គការ ក្នុងរយៈពេល៣០ ថ្ងៃបន្ទាប់ពីបើកឬ បិទ ។ | មាត្រា ១៧ ដល់ មាត្រា ២០ | ជាទំរង់លិខិត រដ្ឋបាល ដែលរៀបចំដោយ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ |
| ២ | NGOs ត្រូវធ្វើសេចក្តីប្រកាសជូនដំណឹង ស្តីពីចលនាបុគ្គលិកក្នុងរយៈពេល ១៥ ថ្ងៃបន្ទាប់ពីទទួលឬឈប់ពីការងារ ។ | មាត្រា ២១ | NGOs = សមាគម និងអង្គការមិនមែនរដ្ឋាភិបាល សំដៅដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក (LNGOs) និងសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស (FNGOs)។ |
| ៣ | NGOs ត្រូវធ្វើសំណើរសុំបើកប្រាក់ឈ្នួលតាមប្រព័ន្ធកុំព្យូទ័រ ។ | មាត្រា ៣៩ ដល់ ៤១ | នៅក្នុងច្បាប់មានចែងអំពីសៀវភៅបើកប្រាក់ តែសម័យកាលបច្ចុប្បន្នការបើកប្រាក់ធ្វើតាមប្រពន្ធធនាគារ។សំណើរសុំបើកប្រាក់ឈ្នួលតាមប្រព័ន្ធកុំព្យូទ័រ ជាទម្រង់លិខិតរដ្ឋបាល។ |
| ៤ | NGOs ត្រូវរៀបចំ ពំពេញតារាងបើកប្រាក់ឈ្នួលប្រចាំខែ ជូនទៅក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ | | ជាតារាង ដែលព្រាងរៀបចំដោយ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ |
| ៥ | NGOs ត្រូវរៀបចំ ការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកប្រចាំស្ថាប័ន នៅពេលដែលស្ថាប័នមានបុគ្គលិកចាប់ពី ៨ នាក់ឡើងទៅ ។ | មាត្រា ២៨៣ ដល់ ២៩៩ | ការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកប្រចាំស្ថាប័ន អនុវត្តតាមប្រកាសលេខ ៣០២ កប/ប្រកគបក របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីប្រតិភូបុគ្គលិកនៅក្នុងសហ |

| | | | |
|---|---|---|---|
| | | | គ្រាស គ្រឹះស្ថាន ចុះថ្ងៃទី ០២ ខែកក្កដា ឆ្នាំ ២០១៨ ។ |
| ៦ | NGOs ត្រូវមានសៀវភៅប្រចាំគ្រឹះស្ថាន ដែលផ្តល់ជូនដោយ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬ អធិការកិច្ចការងារ។ | | សៀវភៅប្រចាំគ្រឹះស្ថាន ប្រើប្រាស់សម្រាប់ អធិការកិច្ចការងារ ។ |
| ៧ | NGOs ត្រូវធ្វើសៀវភៅការងារ និងប័ណ្ណការងារសម្រាប់ កម្មករនិយោជិតខ្មែរ ។ | (មាត្រា ៣២ ដល់ ៣៨) | ជនដែលមានសញ្ជាតិខ្មែរធ្វើការយកឈ្នួលពីនិយោជកណាមួយ ត្រូវតែមានសៀវភៅការងារ ។ សៀវភៅការងារ សំគាល់អត្តសញ្ញាណសាមីខ្លួន ប្រភេទការងារដែលបានចុះកិច្ចសន្យាធ្វើ ថិរវេលាដែលបានចុះកិច្ចសន្យា ប្រាក់ឈ្នួលដែលបានព្រមព្រៀង និងរបៀបបើកប្រាក់ឈ្នួល ។ |
| ៨ | NGOs ត្រូវធ្វើសំណើរសុំចុះទិដ្ឋាការលើបទបញ្ជាផ្ទៃក្នុង ។ | មាត្រា ២២ ដល់ ៣១ | ស្ថាប័នដែលមានកម្មករនិយោជិតយ៉ាងតិច០៨នាក់ត្រូវតែរៀបចំអោយមានបទបញ្ជាផ្ទៃក្នុង ។ បទបញ្ជាផ្ទៃក្នុង អាចជាបទបញ្ជាផ្ទៃក្នុងដែលរៀបចំដោយស្ថាប័ន ឬជាបទបញ្ជាផ្ទៃក្នុងដែលមានទម្រង់ស្រេចចេញពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ |
| ៩ | NGOsត្រូវធ្វើប័ណ្ណការងារនិងសៀវភៅការងារសម្រាប់ជនបរទេស ។ | មាត្រា ២៦១ | គ្មានជនបរទេសណាមកធ្វើការងារនៅព្រះរាជាណាចក្រកម្ពុជា ដោយគ្មានប័ណ្ណការងារ |

| | | | |
|---|---|---|---|
| | | ដល់ ២៦៥ | និងគ្មានសៀវភៅការងារបាន ទេ។ ប័ណ្ណការងារមានសុពលភាពរយៈពេល ០១ ឆ្នាំ ។ ប្រកាសស្តីពី ប័ណ្ណការងារនិងសៀវភៅការងារជនបរទេស លេខ ១៩៥ កប/ប្រក របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី ២០ ខែសីហា ឆ្នាំ ២០១៤ ។ |
| ១០ | NGOs ត្រូវ សុំកូតា សម្រាប់ជនបរទេស ។ | | ប្រកាសលេខ ១៩៥ កប/ប្រក ស្តីពី ការប្រើប្រាស់ហត្ថពលកម្មបរទេស របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី ២០ ខែសីហា ឆ្នាំ ២០១៤។ អត្រាកំណត់អតិបរមា ១០ % បែងចែកតាមប្រភេទ ៖<br>១.និយោជិតការិយាល័យ ៣%<br>២.និយោជិតឬកម្មករឯកទេស ៦%<br>៣.និយោជិតឬកម្មករគ្មានឯកទេស ១% |
| ១១ | ការបើកប្រាក់ឈ្នួល ពីរដង ក្នុងមួយខែ ជូនកម្មករនិយោជិត ចាប់ពីខែមករា ឆ្នាំ ២០១៩ ។ | | ប្រកាស ៤៤២ស្តីពី ការបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ ២០១៨។ |
| ១២ | ការទូទាត់ប្រាក់បំណាច់អតីតភាពការងារ ០២ ដងក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ ២០១៩ ។ | | ប្រកាស ៤៤៣ បក/ប្រក ស្តីពី ការទូទាត់ប្រាក់បំណាច់អតីតភាពការងារ របស់ក្រសួង |

| | | | |
|---|---|---|---|
| | | | ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ ២០១៨។ |
| ១៣ | កាតព្វកិច្ចផ្សេងៗទៀត តាមច្បាប់ និងបទដ្ឋានគតិយុត្ត ជាធរមាន ។ | | មានលិខិតបទដ្ឋានគតិយុត្តជាច្រើន និងវិសោធនកម្មច្បាប់ផងដែរ ដើម្បីសម្របទៅនិងស្ថានភាពសេដ្ឋកិច្ច សង្គមជាក់ស្តែងដែលត្រូវតាមដាន និងអនុវត្ត ។ |
| **ច្បាប់ស្តីពី របបសន្តិសុខសង្គម ( ឆ្នាំ ២០១៩ )** | | | |
| ១ | របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព (អត្រា ២.៦ ភាគរយ នៃប្រាក់ឈ្នួលជាប់ភាគទាន) | មាត្រា ៦ និង មាត្រា ៤ នៃ អនុក្រឹត្យលេខ ១៩៩ អនក្រ.បក ឆ្នាំ ២០២១ | ការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពជំហានទី២ ត្រូវ បានបង្កើតឡើងដោយអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។ របបសន្តិសុខសង្គម ផ្នែកថែទាំសុខភាពមានលក្ខណៈជារបបភាគទានជាកាតព្វកិច្ច ដែល និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ជាអ្នកបង់ភាគទានទាំងស្រុងជូនកម្មករនិយោជិត ដែល មានអត្រា ៖ ២.៦ ភាគរយ នៃប្រាក់ឈ្នួលជាប់ភាគទាន។ |

| | | | |
|---|---|---|---|
| | | | ប្រាក់ឈ្នួលជាប់ភាគទានអប្ប បរមាត្រូវកំណត់ស្មើនឹងចំនួន ៤០០ ០០០(បួនសែន) រៀល និងប្រាក់ ឈ្នួលជាប់ភាគទានពិតានស្មើនិងចំនួន ១ ២០០ ០០០ (មួយលានពីរសែន)រៀល ។ |
| ២ | របបសន្តិសុខសង្គមផ្នែកគ្រោះថ្នាក់ការងារ ឬហានិភ័យការងារ (អត្រា ០.៨ ភាគរយ នៃប្រាក់ឈ្នួលជាប់ភាគទាន) | មាត្រា ៧ និង មាត្រា ៨ នៃ អនុក្រឹត្យ លេខ ១៩៥ អនក្រ .បក ឆ្នាំ ២០២១ | មានលក្ខណៈជារបបភាគទានជាកាតព្វកិច្ច ដែល និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន ជាអ្នកបង់ភាគទានទាំងស្រុងជូនកម្មករនិយោជិត ដែលមានអត្រា ៖ ០.៨ ភាគរយ នៃប្រាក់ឈ្នួលជាប់ភាគទាន។ ប្រាក់ឈ្នួលជាប់ភាគទានអប្បបរមាត្រូវកំណត់ស្មើនឹងចំនួន ៤០០ ០០០(បួនសែន) រៀល និងប្រាក់ ឈ្នួលជាប់ភាគទានពិតានស្មើនិងចំនួន ១ ២០០ ០០០(មួយលានពីរសែន)រៀល ។ |
| ៣ | របបសន្តិសុខសង្គមផ្នែកប្រាក់សោធន ៥ ឆ្នាំដំបូង ៤%(និយោជិត២% និយោជក២%) ក្នុង១ខែ | មាត្រា ៥ និង អនុក្រឹត្យ លេខ ៣២ | របបសន្តិសុខសង្គមផ្នែកប្រាក់សោធន មានលក្ខណៈជាកាតព្វកិច្ច ដែល និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន រួមគ្នាជាមួយ កម្មករនិយោជិត ជាអ្នកបង់ភាគទាន និងចាប់ផ្តើមអនុវត្តនៅខែតុលា ឆ្នាំ២០២២។ |

| | | | |
|---|---|---|---|
| | | | អត្រាភាគទាននៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន ត្រូវបានកំណត់តាមវិធីសាស្ត្របុព្វលាភជណ្តើរ ដូចខាងក្រោម ៖<br>-ដំណាក់កាលទី ១ ៖ ភាគទានត្រូវកំណត់ស្មើនឹង ៤ %(បួនភាគរយ) នៃប្រាក់ឈ្នួលជាប់ភាគទាន ក្នុងរយៈពេល ០៥ (ឆ្នាំ) ដំបូង ។<br>-ដំណាក់កាលទិ២ ៖ ភាគទានត្រូវកំណត់ស្មើនឹង ៨ % នៃប្រាក់ឈ្នួលជាប់ភាគទាន ក្នុងរយៈពេល ០៥ (ឆ្នាំ) បន្ទាប់ពីដំណាក់កាលទី ១ ។<br>-ដំណាក់កាលទី ៣ ៖ អត្រាភាគទានត្រូវដំឡើង ២.៧៥%នៃប្រាក់ឈ្នួលជាប់ភាគទាន ឬប្រាក់ស្មើសុំជាប់ភាគទាន ក្នុងរយៈពេល ១០(ដប់)ឆ្នាំ និងដំណាក់កាល១០(ដប់)ឆ្នាំ បន្តបន្ទាប់។ |
| **និយ័តករគណនេយ្យ និងសវនកម្ម (ន.គ.ស.)** | | | |
| ១ | NGOs ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវកាន់កាប់បញ្ជីគណនេយ្យ និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុអោយបានត្រឹមត្រូវ ស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជា និងស្របតាមប្រកាសលេខ ៣៣៥ សហវ/ប្រក របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០១៨ ស្តីពី ការ | | តាមច្បាប់ស្តីពី គណនេយ្យ និងសវនកម្ម ( ឆ្នាំ ២០១៦) និងច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគា (ឆ្នាំ ២០២១) ។ |

| | | | |
|---|---|---|---|
| | ដាក់អោយអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ។ | | |
| ២ | NGOs ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមក (ន.គ.ស.) តាមពេលកំណត់ដូចខាងក្រោម ៖<br>១.NGOs ដែលរងសវនកម្មឯករាជតាមច្បាប់ ត្រូវបញ្ជូនរបាយការណ៍ហិរញ្ញវត្ថុ រងសវនកម្មឯករាជរួច មក(ន.គ.ស.) ក្នុងអំឡុងពេល ០៦ ខែ ១៥ ថ្ងៃ ក្រោយកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ ។<br>២.NGOs ដែលមិនរងសវនកម្មឯករាជតាមច្បាប់ ត្រូវដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ក្នុងអំឡុងពេល ០៣ ខែ ១៥ ថ្ងៃ ក្រោយកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ ។ | | សេចក្តីណែនាំលេខ ០១០ ន.គ.ស ស្តីពី ការអនុវត្តកាតព្វកិច្ចគណនេយ្យ និងសវនកម្ម សម្រាប់ NGOs |
| ៣ | NGOs ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវស្នើសុំការអនុញ្ញាត្តិពី (ន.គ.ស.) លើការកំណត់យកថ្ងៃបិទបញ្ជីគណនេយ្យខុសពីថ្ងៃទី ៣១ ខែធ្នូ ។ | | សេចក្តីណែនាំលេខ ០១០ ន.គ.ស ស្តីពី ការអនុវត្តកាតព្វកិច្ចគណនេយ្យ និងសវនកម្ម សម្រាប់ NGOs |
| ៤ | NGOs ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវជូនដំណឹងមក (ន.គ.ស.) អំពីភាសាដែលបានប្រើនៅក្នុងប្រព័ន្ធគណនេយ្យកុំព្យូទ័រ ឬប្រព័ន្ធកុំព្យូទ័រពាក់ព័ន្ធ ។ | | NGOs ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញស្ថិតក្នុងលកខណ្ឌដែលបានកំណត់ក្នុងសារាចរលេខ ០០៩ សហវ ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីការប្រើប្រាស់ភាសា និងរូបិយប័ណ្ណក្នុងបញ្ជីគណនេយ្យ និងរបាយការហិរញ្ញវត្ថុ ។ |
| ៥ | NGOs ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវប្រើប្រព័ន្ធអនឡាញ (E-Filling System) របស់ (ន.គ.ស.) | | ស្របតាមប្រកាសលេខ ០០១ អ.ស.ហ.ប្រ.ក ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ ២០២២ ស្តីពីសេវាសាធារណៈរបស់និយ័តការគណនេយ្យ និង |

| | | | |
|---|---|---|---|
| | ដើម្បីដាក់បញ្ជូនរបាយការហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ខ្លួនមក (ន.គ.ស.) និងត្រូវបង់កម្រៃសេវាសាធារណៈ សម្រាប់ការទទួលរក្សាទុករបាយការហិរញ្ញវត្ថុ ។ | | សវនកម្ម (ន.គ.ស.)។ ការខកខាន ឬការយឺតយ៉ាវមិនបានអនុវត្តកាតព្វកិច្ច តាមការកំណត់ខាងលើ អង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវរងទោសទណ្ឌដូចមានចែងក្នុងអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី ០១ ខែមិថុនា ឆ្នាំ ២០២០ ស្តីពី ពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនិងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ។ |

# សេចក្តីសន្និដ្ឋាន

កាតព្វកិច្ច NGOs ឬសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលសំដៅដល់ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក (LNGOs) និង សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស(FNGOs) ដែលបានកំណត់នៅក្នុងច្បាប់ដូចខាងក្រោម ៖

១.ច្បាប់ស្តីពី សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល(ឆ្នាំ ២០១៥)

២.ច្បាប់ស្តីពីសារពើពន្ធ (ឆ្នាំ ១៩៩៧)

៣.ច្បាប់ស្តីពី ការងារ (ឆ្នាំ ១៩៩៧)

៤.ច្បាប់ស្តីពីរបប សន្តិសុខសង្គម(ឆ្នាំ ២០១៩)

៥.និយ័តករគណនេយ្យ និងសវនកម្ម (ន.គ.ស.) តាមច្បាប់ស្តីពី គណនេយ្យនិងសវនកម្ម (ឆ្នាំ២០១៦)និងច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគា (ឆ្នាំ ២០២១) ។

ជាមូលដ្ឋានដើម្បីអោយ NGOs ឬសមាគម និងអង្គការមិនមែនរដ្ឋាភិបាលអនុវត្ត។

ការអនុវត្តកាតព្វកិច្ច តាមច្បាប់អោយបានត្រឹមត្រូវ ជាផ្នែកមួយដ៏សំខាន់ដើម្បីចូលរួមការគោរពនីតិរដ្ឋ និងគេចផុតពីវិធានការផ្នែកច្បាប់ ដែលអាចបង្កើតអោយមានគម្រូល្អសម្រាប់ការអនុវត្តការងារ។

ការមិនបានអនុវត្តកាតព្វកិច្ចតាមច្បាប់អោយបានត្រឹមត្រូវ និងអាចប៉ះពាល់ដល់ការអនុវត្តសកម្មភាពការងាររបស់ស្ថាប័ន ឬអាចឈានដល់ការបិទស្ថាប័ន ។

នៅមានច្បាប់មួយចំនួនទៀតដែល NGOs ត្រូវអនុវត្តក្នុងនាមជាស្ថាប័ន ជានីតិបុគ្គល ដែលច្បាប់បានកំណត់ថាមានសិទ្ធិនិង កាតព្វកិច្ច ដូចជា ច្បាប់ស្តីពីបេឡាជាតិរបបសន្តិសុខសង្គម ច្បាប់ស្តីពីបរធនបាលកិច្ច ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ជាដើម ។

## សេចក្តីបញ្ជាក់

អត្ថបទបង្ហាញនេះ បានធ្វើឡើងដោយមានការឧបត្ថម្ភសប្បុរសធម៌ពីប្រជាពលរដ្ឋអាមេរិក តាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID)។ មាតិកានៃបទបង្ហាញនេះជាការទទួលខុសត្រូវរបស់អង្គការ ជំនួយ ផ្នែកច្បាប់ នៃកម្ពុជា និងមិនឆ្លុះបញ្ចាំងជាចាំបាច់ពីទស្សនៈរបស់ FHI 360 ឬ USAID ឬរដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ។